សហព័ន្ធខ្មែរកម្ពុជាក្រោម
KHMER KAMPUCHEA-KROM FEDERATION
Asia – Europe – North America – Oceania
Office of The President: P.O. Box 39084 • London • ON • N5Y-5L1 • CANADA. • Tel/Fax: (856) 655-2117
http://www.khmerkrom.org • Email: thach.thach@khmerkrom.org

# សេចក្តីអំពាវនាវ

## កសាងមហាសាលា៣ជាន់ នាវត្តសាមគ្គីរង្សី នៅទីក្រុងភ្នំពេញ

យោងតាមសេចក្តីសម្រេច របស់សហព័ន្ធខ្មែរកម្ពុជាក្រោម នាសម័យប្រជុំដំណាច់ឆ្នាំ២០១៣ នៅរដ្ឋផ្លរីដា សហរដ្ឋអាមេរិក កាលពីថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៣ រៀបចំធ្វើបុណ្យផ្កាប្រាក់សាមគ្គី នៅតាមតំបន់ ឬសាខានៃសហព័ន្ធខ្មែរកម្ពុជាក្រោម នៅជុំវិញពិភពលោក ដើម្បីប្រមូលថវិកា យកទៅកសាងមហាសាលា៣ជាន់ នៅវត្តសាមគ្គីរង្សី ស្ថិតនៅភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ ទីក្រុងភ្នំពេញ។

មហាសាលា៣ជាន់នេះ នាំកសាងដោយព្រះតេជព្រះគុណ **កាន សុផានណារិទ្ធ** ព្រះប្រធានសមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានទំហំ **ទទឹង ១៦ ម៉ែត្រ និងបណ្តោយ ៤៦ ម៉ែត្រ** ហើយបច្ចុប្បន្ន កសាងបានសម្រេចជាស្ថាពរមួយជាន់ខាងក្រោម នៅពីរជាន់ខាងលើកំពុងរៀបចំគំរោងដំណើរការសាងសង់ តែនៅខ្វះថវិកាយ៉ាងច្រើន...។

អាស្រ័យហេតុនេះ តាងនាមសហព័ន្ធខ្មែរកម្ពុជាក្រោម សូមអំពាវនាវចំពោះសាខាសហព័ន្ធខ្មែរកម្ពុជាក្រោម នៅជុំវិញពិភពលោក មេត្តាជួយរៀបចំបុណ្យផ្កាប្រាក់សាមគ្គី ឱ្យបានព្រមៗគ្នា នៅតាមតំបន់លោកអ្នករស់នៅ **ចាប់ពីថ្ងៃនេះ រហូតដល់ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៤ ខាងមុខនេះ** ដើម្បីបានថវិកាទាំងអស់នោះ យកទៅកសាងបង្ហើយមហាសាលា ដែលជាមជ្ឈមណ្ឌលសម្រាប់ខ្មែរកម្ពុជាក្រោម។

**ព័ត៌មានបន្ថែម:** សូមបងប្អូនជនរួមជាតិ ទំនាក់ទំនងការិយាល័យ វិទ្យុសំឡេងកម្ពុជាក្រោម តាមទូរស័ព្ទលេខ **៤០៨ ៥៥០-៥០៦០** ។

សូមបងប្អូនជនរួមជាតិ ទទួលនូវការស្រឡាញ់រាប់អានពីខ្ញុំព្រះករុណាខ្ញុំបាទ។

ធ្វើនៅកាណាដា ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០១៣

**ថាច់ ង៉ុក ថាច់**

ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម